ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance
សំណុំរឿងលេខ ០០២/១៩ កញ្ញា ឆ្នាំ ២០០៧/អវតក/អជសដ
Case File/Dossier No. 002/19-09-2007/ECCC/TC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Jun-2019, 10:48
CMS/CFO: Sann Rada

| | |
|---|---|
| ចំពោះមុខ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Martin KAROPKIN** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ | ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ |
| ភាសាដើម | ខ្មែរ/អង់គ្លេស |
| ប្រភេទឯកសារ | សាធារណៈ |

---

# ដីកាបង្គាប់ឲ្យធ្វើចំណាត់ថ្នាក់ប្រភេទឡើងវិញនៅលើឯកសារនានានៅក្នុងសំណុំរឿង មកជាឯកសារសាធារណៈ

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

**<u>ជនជាប់ចោទ</u>**

នួន ជា
ខៀវ សំផន

**<u>មេធាវីការពារក្តី</u>**

សុន អរុណ
លីវ សុវណ្ណា
Doreen CHEN
គង់ សំអុន
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ("អនុស្សរណៈ") ដោយជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណឯកសារចំនួន ១.៤៣៩ ជាឯកសារសម្ងាត់ដែលត្រូវបានយោង ឬដកស្រង់នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០២។ ប្រធានអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះយល់ឃើញថា ចំណាត់ប្រភេទឯកសារទាំងនេះជាឯកសារសម្ងាត់លែងមានភាពចាំបាច់ទៀតហើយ ក្នុងកិច្ចដំណើរការនីតិវិធីនៅដំណាក់កាលនេះ និងបានស្នើដល់ភាគី រួមទាំងសហចៅក្រមស៊ើបអង្កេត និងចៅក្រមនៃអង្គបុរេជំនុំជម្រះឱ្យផ្តល់មតិយោបល់អំពីភាពចាំបាច់ដែលត្រូវរក្សាឋានៈឯកសារទាំងនេះជាឯកសារសម្ងាត់[1]។

## ២. ច្បាប់ជាគោល

២. អនុលោមតាមមាត្រា ៣.១៤ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក. និងមាត្រា ៩.១ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទនិងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង អង្គជំនុំជម្រះដែលទទួលសំណុំរឿងយកមកពិនិត្យ អាចចេញដីកាបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញ ទៅលើឯកសារនានានៅក្នុងសំណុំរឿង។ ភាគីដែលពាក់ព័ន្ធនឹងមានឱកាសក្នុងការបញ្ចេញមតិយោបល់មុនពេលចេញដីកាសម្រេចនេះ។

៣. អនុលោមតាមមាត្រា ៤ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទ និងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ប្រភេទឯកសារនិងព័ត៌មាននានាដូចខាងក្រោម (ក្នុងចំណោមឯកសារនិងព័ត៌មានជាច្រើនទៀត) ជាគោលការណ៍ ត្រូវចាត់ថ្នាក់ជាឯកសារនិងព័ត៌មាន*សាធារណៈ* លើកលែងតែមានចំណាត់ថ្នាក់ផ្សេងពីនេះ ទៅតាមសេចក្តីសម្រេចរបស់តុលាការឬការកាត់ចេញផ្នែកខ្លះ ក្នុងករណីចាំបាច់៖

គ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតសំឡេង/រូបភាពនៃសវនាការសាធារណៈ។

ឃ. ភស្តុតាងដែលរួមមានរបាយការណ៍ជំនាញ ដែលត្រូវបានទទួលយកនៅក្នុងអំឡុងពេលជំនុំជម្រះឬនៅពេលដែលប្តឹងឧទ្ធរណ៍។ និង

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងមានចំណងជើងថា ឯកសារសម្ងាត់នៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០២ ដែល ស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ ឯកសារ E467 ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩។

ង. សាលក្រមនិងសេចក្ដីសម្រេចនានារបស់អង្គជំនុំជម្រះ។

៤. អនុលោមតាមមាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីចំណាត់ប្រភេទនិងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង ប្រភេទឯកសារ និងព័ត៌មាននានាដូចខាងក្រោម (ក្នុងចំណោមឯកសារនិងព័ត៌មានជាច្រើនទៀត) ជាគោលការណ៍ ត្រូវចាត់ថ្នាក់ជាឯកសារនិងព័ត៌មាន*សម្ងាត់* និងស្ថិតក្នុងលក្ខខណ្ឌដូចគ្នា៖

ខ. អនុលោមតាមមាត្រា ៤ សំណុំឯកសារដែលទទួលបាននិងភស្តុតាងដែលបានផ្ដល់ឱ្យនៅដំណាក់កាលស៊ើបសួររបស់តុលាការ។

គ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតសំឡេង/រូបភាពនៃការធ្វើសម្ភាសន៍ និងសកម្មភាពស៊ើបសួរផ្សេងៗ ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតឬអ្នកដែលទទួលបានសិទ្ធិឱ្យស៊ើបសួរជំនួស។

ឃ. បណ្ដឹងរបស់ជនរងគ្រោះ។

ង. អត្តសញ្ញាណ អាសយដ្ឋានលម្អិតរបស់ជនរងគ្រោះ ដែលមិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណី (ដែលរួមមានបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី)។

ច. សេចក្ដីសម្រេច ដីកា និងកិច្ចដទៃទៀតរបស់សហចៅក្រមស៊ើបអង្កេត។

ឆ. កំណត់ហេតុជាលាយលក្ខណ៍អក្សរ ប្រតិចារឹក ការថតសំឡេង/រូបភាពនៃសវនាការជាសម្ងាត់។

## ៣. ការពិភាក្សា

៥. អនុស្សរណៈបានផ្ដល់ឱកាសដល់ភាគីក្នុងការឆ្លើយតបទៅនឹងសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារដែលមានក្នុងតារាងឧបសម្ព័ន្ធ។ សហព្រះរាជអាជ្ញា មេធាវីការពារក្ដី នួន ជា និង សហចៅក្រមស៊ើបអង្កេតមិនបានដាក់មតិយោបល់ណាមួយទៅលើសំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនេះទេ។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ពួកគាត់ពុំជំទាស់ទៅលើការធ្វើចំណាត់ថ្នាក់នេះឡើយ[2]។ ភាគីដែលបានឆ្លើយតបទៅនឹងអនុស្សរណៈ (សូមមើលខាងក្រោម) ពុំមានលើកឡើងនូវការជំទាស់ទៅនឹងឧបសម្ព័ន្ធ (គ) និង(ឃ) ទេ។ ដូច្នេះ អង្គជំនុំជម្រះបញ្ចូលឧបសម្ព័ន្ធទាំងនេះជា **ឧបសម្ព័ន្ធ ៣ និង ៤** ហើយបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារនានាដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធទាំងនេះ។

---

[2] *សូមមើល* អនុស្សរណៈ កថាខណ្ឌ ៦។

## ៣.១. ចម្លើយតបរបស់ ខៀវ សំផន ទៅនឹងអនុស្សរណៈ

៦. នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តី ខៀវ សំផន បានដាក់មតិយោបល់របស់ខ្លួនជាការឆ្លើយតបទៅនឹងអនុស្សរណៈ ដោយបានបង្ហាញថា ខ្លួន "មិនជំទាស់នឹងការស្នើសុំធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញទេ"។ ក្រៅពីនេះ មេធាវីការពារក្តីបានកំណត់អត្តសញ្ញាណឯកសារចំនួន ១២ ក្នុងចំណោមឯកសារនានាដែលខ្លួនបានដាក់ពីមុន ដែលត្រូវបានធ្វើចំណាត់ប្រភេទជាឯកសារសម្ងាត់ ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើចំណាត់ប្រភេទឯកសារទាំងនោះឡើងវិញជាឯកសារសាធារណៈ [3]។

៧. នៅក្នុងអនុស្សរណៈរបស់ខ្លួន ប្រធានអង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា នៅពេលនេះ ពុំមានឯកសារណាផ្សេងក្រៅតែពីឯកសារដែលយកមកយោងនៅក្នុងសាលក្រមនៃសំណុំរឿង ០០២/០២ ប៉ុណ្ណោះ ដែលត្រូវបានយកមកពិចារណាធ្វើចំណាត់ប្រភេទឡើងវិញ។ ដីកាសម្រេចនេះត្រូវបានធ្វើឡើងក្រោយការកាត់បន្ថយបុគ្គលិករបស់អង្គជំនុំជម្រះ បន្ទាប់ពីចេញសាលក្រម និងពេលវេលាតិចតួចដែលអង្គជំនុំជម្រះសាលាដំបូងនៅមានយុត្តាធិការរហូតដល់ពេលដែលភាគីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ និងសំណុំ-រឿងត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូល អនុលោមតាមវិធាន ១០៨(១) នៃវិធានផ្ទៃក្នុង[4]។

៨. ជាការកត់សម្គាល់ ឯកសារទាំង ១២ ដែលមេធាវីការពារក្តីបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញ បង្កើតជាផ្នែកនៃការដាក់សំណុំឯកសារជាច្រើនបន្តបន្ទាប់ ដែលឯកសារភាគច្រើនក៏ត្រូវបានធ្វើ

---

[3] អនុស្សរណៈរបស់មេធាវីការពារក្តី ខៀវ សំផន មានចំណងជើងថា មតិយោបល់លើសំណើសុំធ្វើចំណាត់ប្រភេទឯកសារសម្ងាត់ឡើងវិញ ឯកសារ E467/1 ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩។

[4] ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន បានបង្ហាញចេតនារបស់ពួកគេក្នុងការប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២។ *សូមមើល* សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំបន្ថែមចំនួនទំព័រ និងពេលវេលាសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ F40/1.1 ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។ លិខិតរបស់ នួន ជា ផ្តល់សិទ្ធិឱ្យមេធាវីរបស់គាត់ធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០២ ឯកសារ E465/1 ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩។ សំណើរបស់ ខៀវ សំផន សុំពន្យារពេល និងបន្ថែមចំនួនទំព័រនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឯកសារ F39/1.1 ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩។ សំណើរបស់ ខៀវ សំផន សុំឱ្យពិនិត្យឡើងវិញលើសេចក្តីសម្រេចស្តីពីការសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឯកសារ F44 ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។ *សូមមើល* សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញចំពោះសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រដើម្បីដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ឯកសារ F44/1 ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩។

ចំណាត់ប្រភេទជាឯកសារសម្ងាត់ផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា បើគ្មានការពិនិត្យឱ្យបានទូលំទូលាយទៅលើឯកសារសម្ងាត់ទាំងអស់នៅក្នុងសំណុំរឿងទេនោះ ការធ្វើចំណាត់ប្រភេទឯកសារឡើងវិញមួយផ្នែកទៅលើឯកសាររបស់ភាគីតែមួយ ទៅតាមការស្នើសុំរបស់មេធាវីការពារក្តី ខៀវ សំផន នឹងមិនបង្ហាញនូវតម្លាភាពគ្រប់គ្រាន់ទេ។

៩. អង្គជំនុំជម្រះតុលាការកំពូល ក្នុងឋានៈជាអង្គជំនុំជម្រះចុងក្រោយបង្អស់ដែលទទួលយកសំណុំរឿង ០០២/០២ ទៅពិនិត្យ នឹងមានភារកិច្ចពិនិត្យឡើងវិញឱ្យបានទូលំទូលាយទៅលើការធ្វើចំណាត់ប្រភេទចំពោះឯកសារទាំងអស់នៅក្នុងសំណុំរឿង បន្ទាប់ពីបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ[5]។ ក្នុងករណីដែលភាគីណាមួយយល់ឃើញថា ជាការចាំបាច់ដែលត្រូវដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញឱ្យបានឆាប់ ពួកគេនឹងមានឱកាសក្នុងការស្នើសុំបែបនេះនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល នៅពេលដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណុំរឿង។

## ៣.២. ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងអនុស្សរណៈ

១០. នៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបទៅនឹងអនុស្សរណៈ ដោយបង្ហាញថា ពួកគេមិនជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឯកសារជាសាធារណៈនូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនិងទម្រង់បែបបទព័ត៌មានបន្ថែមនៅក្នុងឧបសម្ព័ន្ធ (ក) នោះទេ ប្រសិនបើមានការកោសលុបឯកសារទាំងនោះយ៉ាងសមស្រប អនុលោមតាមមាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទឯកសារនិងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង[6]។

១១. អង្គជំនុំជម្រះបានកំណត់អត្តសញ្ញាណពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់បែបបទព័ត៌មានបន្ថែមជាច្រើននៅក្នុងឧបសម្ព័ន្ធ (ក) ដែលអាចតម្រូវឱ្យមានការកោសលុបចំពោះព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងរបស់ម្ចាស់បណ្តឹងនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមមាត្រា ៧.៤ នៃសេចក្តីណែនាំអនុវត្ត។ ដូចបានលើកឡើងខាងលើ អង្គជំនុំជម្រះសាលាដំបូងពុំមានបុគ្គលិក

---

5 សេចក្តីណែនាំអនុវត្តស្តីពីចំណាត់ប្រភេទនិងការគ្រប់គ្រងព័ត៌មានទាក់ទងនឹងសំណុំរឿង មាត្រា ១២.២។

6 មតិយោបល់ និងការជំទាស់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ឯកសារសម្ងាត់នៅក្នុងសាលក្រមនៃសំណុំរឿង០០២/០២ដែលស្នើសុំឱ្យមានការធ្វើចំណាត់ប្រភេទឡើងវិញ ជាឯកសារសាធារណៈ" ឯកសារ E467/2 ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ កថាខណ្ឌ ២ ("អនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី")។

និងពេលវេលាគ្រប់គ្រាន់ដើម្បីវាយតម្លៃនិងកោសលុបឯកសារទាំងនេះទេ។ ហេតុនេះ អង្គជំនុំជម្រះបានដកឯកសារពាក់ព័ន្ធចេញពីឧបសម្ព័ន្ធ (ក) និងបញ្ចូលឯកសារទាំងនោះទៅក្នុង **ឧបសម្ព័ន្ធ ៥** នៃដីកាបង្គាប់នេះវិញ។ អង្គជំនុំជម្រះតុលាការកំពូលមានភារកិច្ចពិនិត្យឡើងវិញទៅលើភាពសមស្របនៃការធ្វើចំណាត់ថ្នាក់នៃឯកសារទាំងនេះរួមមាន ការកោសលុបនានា តាមការផ្តួចផ្តើមរបស់ខ្លួនឬនៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខ លើកលែងតែសហមេធាវីនាំមុខ (ឬភាគីផ្សេងទៀត) ដាក់សំណើសុំបែបនេះតាំងពីដំបូងមក។ អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញចំពោះឯកសារដែលនៅសេសសល់ក្នុងឧបសម្ព័ន្ធ (ក) នៃអនុស្សរណៈ ដែលត្រូវបានបញ្ចូលជា**ឧបសម្ព័ន្ធ ១** វិញ។

១២. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញចំពោះឧបសម្ព័ន្ធនានានៃបណ្តឹងទាមទារសំណងចុងក្រោយរបស់ខ្លួន (ឯកសារ E457/6/2) និងសេចក្តីសន្និដ្ឋានបន្ថែមស្តីពីបញ្ហាមូលនិធិពាក់ព័ន្ធនឹងគម្រោងសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើសុំគោលការណ៍ណែនាំ (ឯកសារ E457/6/2/4) ដូចបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ខ នៃអនុស្សរណៈ[7]។ អង្គជំនុំជម្រះសង្កេតឃើញថា ការដាក់ឧបសម្ព័ន្ធទាំងនេះជាឯកសារសម្ងាត់ គឺធ្វើតាមការអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ [8]។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា ឯកសារនានាដែលសហមេធាវីនាំមុខយកមកសំអាង មានព័ត៌មានអំពីការរៀបចំផ្នែកហិរញ្ញវត្ថុរបស់អង្គការខាងក្រៅនិងកិច្ចសន្យាជាមួយភាគីទីបី ហើយយល់ស្របជាមួយនឹងសហមេធាវីនាំមុខដែលថា ការធ្វើចំណាត់ប្រភេទឯកសារទាំងនោះជាឯកសារសាធារណៈនៅដំណាក់កាលនេះពុំសមស្របទេ។ ហេតុនេះ អង្គជំនុំជម្រះបានដកឯកសារចំនួន ១៦ ចេញពីឧបសម្ព័ន្ធ (ខ) នៃអនុស្សរណៈ ហើយបញ្ចូលឯកសារដែលនៅសេសសល់ធ្វើជា**ឧបសម្ព័ន្ធ ២** វិញ និងបង្គាប់ឱ្យធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញ។

១៣. ចុងក្រោយ សហមេធាវីនាំមុខជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញចំពោះឯកសារ E344.1 ដោយសារឯកសារនេះមានព័ត៌មានលម្អិតសម្រាប់ទំនាក់ទំនងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីមួយរូប [9]។ ឯកសារនេះមិនត្រូវបានបញ្ចូលនៅក្នុងឧបសម្ព័ន្ធណាមួយដែលភ្ជាប់ជាមួយអនុស្សរណៈទេ ហើយក៏មិនត្រូវបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅដំណាក់កាលនេះដែរ។

---

[7] អនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣។

[8] *សូមមើល* ឧបសម្ព័ន្ធ ១-១៣ ឯកសារ E218/7/6.1.1 ដល់ឯកសារ E218/7/6.1.10។

[9] អនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៤។

01618661



## ៣.៣. ចម្លើយតបរបស់អង្គបុរេជំនុំជម្រះទៅនឹងអនុស្សរណៈ

១៤. នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងអនុស្សរណៈ[10]។ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានបញ្ជាក់ថា ពួកគាត់មិនជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញចំពោះឯកសារសម្ងាត់ទេ "លើកលែងតែឈ្មោះនិងព័ត៌មានផ្ទាល់ខ្លួនរបស់សាក្សីដែលស្ថិតក្រោមវិធានការការពារឬរបស់អ្នកដែលសំណើសុំវិធានការការពារកំពុងរង់ចាំការសម្រេច"។ លើសពីនេះ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានស្នើសុំការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈ "ចំពោះរាល់សេចក្តីសម្រេចផ្សេងទៀតរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង 00២ ដែលបច្ចុប្បន្នជាប្រភេទឯកសារសម្ងាត់" ស្របតាមលក្ខខណ្ឌដូចបានគូសបញ្ជាក់ខាងលើ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះបានបញ្ចូលឧបសម្ព័ន្ធចំនួនពីរ ដោយមានឯកសារចំនួន ១០៦ ដែលពួកគាត់បានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញ[11]។

១៥. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពុំមានឯកសារណាមួយក្នុងចំណោមឯកសារដែលបានស្នើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញនៅក្នុងអនុស្សរណៈរបស់ខ្លួន ជាប់ពាក់ព័ន្ធនឹងសាក្សីដែលត្រូវបានការពារនៅក្នុងសំណុំរឿង 00១ ឬសំណុំរឿង 00២ នោះឡើយ។ ជាងនេះទៀត អង្គជំនុំជម្រះកំពុងតែមានយុត្តាធិការលើសំណុំរឿង 00២/0២ ប៉ុណ្ណោះ ហើយមិនអាចចូលពិនិត្យមើលវិធានការការពារដែលត្រូវបានអនុញ្ញាតឬដែលកំពុងរង់ចាំការសម្រេចពីអង្គភាពតុលាការផ្សេងទៀតនៅក្នុងសំណុំរឿង 00៣ និងសំណុំរឿង 00៤ ឡើយ។

១៦. ចំពោះសាក្សីនានាដែលអាចត្រូវបានការពារនៅក្នុងសំណុំរឿង 00៣ និងសំណុំរឿង 00៤ អង្គជំនុំជម្រះយោងទៅការណែនាំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ.") អំពីការយោងជាសាធារណៈ (ក្នុងអំឡុងពេលធ្វើសេចក្តីថ្លែងបិទបញ្ចប់កិច្ចពិភាក្សាដេញដោល) ចំពោះកំណត់ហេតុជាលាយ-

---

[10] អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ មានចំណងជើងថា ចម្លើយតបចំពោះអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "សំណើចំណាត់ថ្នាក់ប្រភេទឯកសារសម្ងាត់នៅក្នុងសេចក្តីសម្រេចនៃសំណុំរឿង00២/0២ ទៅជាសាធារណៈ" ឯកសារ E467/5 ចុះថ្ងៃទី២១ខែឧសភា ឆ្នាំ២០១៩ ("អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ")។ អង្គបុរេជំនុំជម្រះបានស្នើសុំនិងទទួលបានការពន្យារពេលដាក់ចម្លើយតបរបស់ខ្លួននៅថ្ងៃទី0៨ ខែឧសភា ឆ្នាំ២០១៩ (*សូមមើល* ឯកសារ E467/3)។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងបានបដិសេធទទួលយកឯកសារលើកទីមួយរបស់អង្គបុរេជំនុំជម្រះ ដោយសារពុំឃើញមានបោះត្រាឬចុះហត្ថលេខារបស់ចៅក្រមនៃអង្គបុរេជំនុំជម្រះ និងមានភាពមិនស៊ីចង្វាក់ទាក់ទិននឹងឯកសារដើម (ឯកសារ E467/4)។

[11] អនុស្សរណៈរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ២-៣។

លក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ("កំណត់ហេតុស្តាប់ចម្លើយ") ពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដែលត្រូវបានដាក់បង្ហាញទៅក្នុងសំណុំរឿង ០០២[12]។ ស.ច.ស.អ. បានលើកឡើងថា៖

> មិនមានពេលណាមួយ [នៅក្នុងអនុស្សរណៈមុនៗរបស់ ស.ច.ស.អ.] ដែលមានការពិភាក្សាអំពីការចេញផ្សាយជាសាធារណៈនូវខ្លឹមសារទាំងស្រុងនៃឯកសារពាក់ព័ន្ធទាំងនោះឡើយ ប៉ុន្តែ មានតែផ្នែកនានាដែលពាក់ព័ន្ធតែប៉ុណ្ណោះ ដូចដែលភាគី និងអង្គជំនុំជម្រះបានប្រើប្រាស់នៅក្នុងសវនាការ និងក្នុងគោលបំណងរៀបចំសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ហើយចុងក្រោយបង្អស់ គឺសាលក្រម [សំណុំរឿង ០០២/០២]។ មូលហេតុគឺដោយសារកំណត់ហេតុស្តាប់ចម្លើយដដែលនេះនៅតែជាឯកសារសម្ងាត់នៅក្នុងសំណុំរឿងដើមគឺសំណុំរឿង ០០៣, សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២។ [...] ការធ្វើចំណាត់ថ្នាក់ឯកសារទាំងនោះឡើងវិញទៅជាឯកសារសាធារណៈនៅក្នុងសំណុំរឿង ០០២/០២ នោះនឹងធ្វើឱ្យឯកសារមួយចំនួននៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ទៅជាឯកសារសាធារណៈដែរ ដោយពុំចាំបាច់ធ្វើឱ្យឯកសារទាំងនោះទៅជាឯកសារសាធារណៈទៀតឡើយ[13]។

១៧. ហេតុនេះ ស.ច.ស.អ. បានជំទាស់ទៅនឹងការធ្វើចំណាត់ប្រភេទឡើងវិញជាឯកសារសាធារណៈនៅក្នុងសំណុំរឿង ០០២/០២ ចំពោះកំណត់ហេតុស្តាប់ចម្លើយដែលបានធ្វើឡើងនៅក្នុងសំណុំរឿង ០០៣

---

[12] *សូមមើល ឧទាហរណ៍* អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានចំណងជើងថា អនុស្សរណៈថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ឯកសារ E319/35/11 ដែលបានជូនដំណឹងដល់ ស.ច.ស.អ. នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧ ឯកសារ E319/35/14/2 ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៨។ អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានចំណងជើងថា ការពិនិត្យឡើងវិញទៅលើការកម្រិតអំពីភាពជាសម្ងាត់នៃសម្ភារៈនៅក្នុងសំណុំរឿង ០០៣ និង សំណុំរឿង ០០៤ អនុលោមទៅតាមសំណើរបស់ ក.ស.ព. E319/35/10 ឯកសារ E319/35/14/3 ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧។ អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានចំណងជើងថា អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "អនុស្សរណៈសុំការបញ្ជាក់បំភ្លឺអំពីអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ E319/35/14/3" ឯកសារ E319/35/15/2 ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨។

[13] អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានចំណងជើងថា អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "អនុស្សរណៈសុំការបញ្ជាក់បំភ្លឺអំពីអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ E319/35/14/3" ឯកសារ E319/35/15/2 ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ កថាខណ្ឌ ៥, ៨។

01618663



និងសំណុំរឿង០០៤[14]។អង្គជំនុំជម្រះយល់ឃើញថាការជំទាស់របស់ស.ច.ស.អ.នៅមានសុពលភាពដដែល ទាក់ទិននឹងសំណុំរឿង ០០៤ ដែលកំពុងស្ថិតក្នុងដំណាក់កាលស៊ើបអង្កេតនៅឡើយ ហេតុដូច្នេះ សំណុំរឿងនេះត្រូវស្ថិតនៅក្នុងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតដដែល[15]។

១៨. នាពេលបច្ចុប្បន្ន អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤/០២ មកពិនិត្យ ហេតុនេះ អង្គបុរេជំនុំជម្រះជាអ្នកគ្រប់គ្រងសំណុំរឿងទាំងនេះ[16]។ អង្គបុរេជំនុំជម្រះគឺជាអង្គជំនុំជម្រះសមស្របជាងគេ ដែលត្រូវផ្តល់មតិយោបល់ទៅលើផលប៉ះពាល់នៃវិធានការការពារនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤/២ ដែលអាចមានទៅលើកំណត់ហេតុស្តាប់ចម្លើយនានា ដែលត្រូវបានយកមកដាក់បង្ហាញនៅក្នុងសំណុំរឿង ០០២/០២ ហើយដែលនៅពេលនេះ ឯកសារទាំងនេះត្រូវបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញ។ អង្គជំនុំជម្រះសាលាដំបូងបានដកកំណត់ហេតុស្តាប់ចម្លើយទាំងអស់ចេញពីឧបសម្ព័ន្ធ (ក) ហើយបញ្ចូលឯកសារទាំងនេះជាឧបសម្ព័ន្ធថ្មីវិញគឺ**ឧបសម្ព័ន្ធ ៦** ភ្ជាប់ជាមួយដីកាបង្គាប់នេះ។ អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យអង្គបុរេជំនុំជម្រះពិនិត្យឡើងវិញទៅលើកំណត់ហេតុស្តាប់ចម្លើយនានាដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៦ ព្រមទាំងសេចក្តីសម្រេចនានាដែលភ្ជាប់ជាមួយអនុស្សរណៈរបស់ខ្លួន ដែលត្រូវបានស្នើសុំឱ្យធ្វើចំណាត់ប្រភេទឡើងវិញ [17] និងជូនដំណឹងទៅអង្គជំនុំជម្រះតុលាការកំពូលក្នុងពេលសមស្រប អំពីភាពចាំបាច់នៃការធ្វើចំណាត់ប្រភេទឯកសារទាំងនេះឡើងវិញជាឯកសារសាធារណៈ ដែលត្រូវមានការកោសលុបក្នុងករណីចាំបាច់។

---

[14] អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានចំណងជើងថា អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង "អនុស្សរណៈសុំការបញ្ជាក់បំភ្លឺអំពីអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ E319/35/14/3" ឯកសារ E319/35/15/2 ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ កថាខណ្ឌ ១១។

[15] វិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ("សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ")។ ដីកាដំណោះស្រាយត្រូវបានរំពឹងថានឹងចេញនៅត្រីមាសទីពីរឆ្នាំ២០១៩។ *សូមមើល*ផែនការបញ្ចប់សំណុំរឿងនៅចំពោះមុខ អ.វ.ត.ក. វិសោធនកម្មលើកទី២០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ អាចរកបាននៅគេហទំព័រ https://eccc.gov.kh/en/completion-plan-revision-20 ។

[16] អង្គបុរេជំនុំជម្រះបានប្រកាសថា សហចៅក្រមស៊ើបអង្កេតលែងមានសិទ្ធិទៀតហើយ *(functus officio)* ក្រោយពេលចុះហត្ថលេខាទៅលើដីកាដំណោះស្រាយរួច។ *សូមមើល* សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) (សំណុំរឿង ០០៤/០១) ឯកសារ D308/3/1/20 ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៣។

[17] សូមមើលខាងលើ កថាខណ្ឌ ១៤។

**ផ្អែកតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**បង្គាប់**ឱ្យអង្គភាពបណ្ណសារធ្វើចំណាត់ប្រភេទឯកសារឡើងវិញជាឯកសារសាធារណៈ នូវឯកសារនានាដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ១, ២, ៣ និង ៤។

**ពន្យារពេល**ចេញសេចក្ដីសម្រេចស្ដីពីការធ្វើចំណាត់ប្រភេទឡើងវិញចំពោះឯកសារនានាដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៥ និងសំណុំឯកសារចំនួន ១២ ដែលមេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំ។

**ស្នើ**អង្គបុរេជំនុំជម្រះ ធ្វើការពិនិត្យឡើងវិញទៅលើកំណត់ហេតុស្ដាប់ចម្លើយនានាដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ៦ និងសេចក្ដីសម្រេចនានាដែលភ្ជាប់មកជាមួយអនុស្សរណៈរបស់ខ្លួន និងដោយពិចារណាទៅលើវិធានការការពារដែលបានអនុម័តនៅក្នុងសំណុំរឿង 00៣ និងសំណុំរឿង 00៤ ឱ្យជូនដំណឹងដល់អង្គជំនុំជម្រះតុលាការកំពូលក្នុងពេលវេលាសមស្រប អំពីភាពចាំបាច់នៃការកោសលុប និងភាពចាំបាច់នៃការបន្តរក្សាចំណាត់ប្រភេទឯកសារទាំងនេះជាឯកសារសម្ងាត់។

ភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE DE PREMIÈRE INSTANCE

**និល ណុន**